**Compliance Advisor/Ombudsman**
**2121 Pennsylvania Ave., N.W.**
**Washington, D.C. 20433**
**U.S.A.**

# របាយការណ៍ស្តីពីវឌ្ឍនភាពរបស់ការិយាល័យ ស៊ីអេអូ

ប្រទេសកម្ពុជា ៖ *VEIL II-01*/ខេត្តរតនៈគិរី

ខែកក្កដា ឆ្នាំ២០១៦

## សាវតានៃពាក្យបណ្តឹង

**ការវិនិយោគរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)**

មូលនិធិវិនិយោគសហគ្រាសវៀតណាម (“VEIL” ឬ “មូលនិធិ”) គឺជាមូលនិធិវិនិយោគមួយមានម្ចាស់ហ៊ុនតិច ដែលមានប្រតិបត្តិការចាប់តាំងពីឆ្នាំ១៩៩៥មក។ មូលនិធិនេះមានមូលដ្ឋានមូលធនជាង ៥០០ លានដុល្លារសហរដ្ឋអាមេរិកប៉ុណ្ណោះ និង គ្រប់គ្រងដោយក្រុមហ៊ុនដ្រេហ្គិនខាភីថលម៉ាណេជមិន អិលធីឌី ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធមួយ នៃក្រុមហ៊ុនដ្រេហ្គិនខាភីថលគ្រុប (DCG)។ IFC បានវិនិយោគទឹកប្រាក់ចំនួន ១៦,៤ លានដុល្លារសហរដ្ឋអាមេរិក ទៅក្នុងមូលនិធិនេះ។ មូលនិធិនេះមានគោលបំណងវិនិយោគទៅលើមូលប័ត្ររបស់ក្រុមហ៊ុនវៀតណាម ដែលត្រូវបានផ្តល់ជូនពីប្រភពវិស័យសាធារណៈ ឬ វិស័យឯកជន ក្នុងគោលបំណងផ្តល់ការលើកទឹកចិត្តសម្រាប់ការអភិវឌ្ឍន៍ទីផ្សារមូលធនវៀតណាម តាមរយៈការបង្កើនសាច់ប្រាក់របស់មូលប័ត្រវៀតណាម។ ក្រុមហ៊ុនមួយដែល DCG បានធ្វើការវិនិយោគតាមរយៈមូលនិធិនេះ គឺក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ (HAGL) ។

## ពាក្យបណ្តឹង

ក្នុងខែកុម្ភៈ ឆ្នាំ២០១៤ មានប្រជាពលរដ្ឋក្នុមូលដ្ឋានចំនួន ១៧ភូមិ ក្នុងខេត្តរតនៈគិរី បានដាក់ពាក្យបណ្តឹងទៅកាន់ការិយាល័យ ស៊ីអេអូ ដោយមានកិច្ចគាំទ្រ និងជំនួយពីអង្គការមិនមែនរដ្ឋាភិបាលចំនួន៥។ ពាក្យបណ្តឹងបានលើកឡើងអំពីការព្រួយបារម្ភចំពោះបញ្ហាផ្នែកបរិស្ថាន និងសង្គមមួយចំនួន ទាក់ទងនឹងប្រតិបត្តិការរបស់ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយក្នុប្រទេសកម្ពុជា ក្នុងនោះរួមមាន ផលប៉ះពាល់ទៅលើប្រភពទឹក និងត្រី ការបាត់បង់ដីធ្លី កង្វះការផ្តល់ប្រាក់សំណង កង្វះការបើកចំហព័ត៌មាន និងការចូលរួមពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន ការគំរាមកំហែងចំពោះការអនុវត្តន៍សៃនព្រៃដល់អារក្ស ការប្រតិបត្តិផ្នែកវប្បធម៌ និងការប្រតិបត្តិរបស់ជនជាតិដើមភាគតិច ព្រមទាំងការប្រើប្រាស់ពលកម្មកុមារ។ ពាក្យបណ្តឹងបានចោទប្រកាន់អំពីភាពមិនអនុលោមទៅនឹងគោលនយោបាយ និងនីតិវិធីរបស់ IFC ព្រមទាំងច្បាប់របស់កម្ពុជា។ ដើមបណ្តឹងបានស្នើសុំឱ្យការិយាល័យ ស៊ីអេអូ រក្សាការសម្ងាត់ចំពោះអត្តសញ្ញាណរបស់ពួកគេ។

## ដំណើរការរបស់ការិយាល័យ ស៊ីអេអូ

### ការប៉ាន់ប្រមាណ

ពាក្យបណ្តឹងត្រូវបានកំណត់ថា មានលក្ខខណ្ឌសមស្របសម្រាប់ធ្វើការប៉ាន់ប្រមាណបន្ថែមទៀត ក្នុងខែកុម្ភៈ ឆ្នាំ២០១៤ ហើយក្រុមការងាររបស់ការិយាល័យ ស៊ីអេអូ បានធ្វើដំណើរទៅមូលដ្ឋាន ក្នុងខែមីនា ដើម្បីជួបជាមួយអ្នកពាក់ព័ន្ធ ក្នុងគោលបំណងស្វែងរកជម្រើសនានាសម្រាប់ដំណោះស្រាយមួយបែបសហការចំពោះបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង។

សហគមបានលើកឡើងអំពីការព្រួយបារម្ភចំពោះផលប៉ះពាល់នាពេលបច្ចុប្បន្ន និង អនាគតទៅលើជីវភាពរស់នៅ និងសិទ្ធិរបស់ពួកគេ។ ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ បានប្តេជ្ញាដោះស្រាយបញ្ហាដែលបានលើកឡើង និងកំណត់យកប្រយោជន៍របស់សហគមជាអាទិភាព។ ក្នុងខែមេសា ឆ្នាំ២០១៤ ភាគីបានបង្ហាញអំពីឆន្ទៈរបស់ពួកគេក្នុងការចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទបែបស្ម័គ្រចិត្តមួយ ដែលផ្តួចផ្តើមឡើងដោយការិយាល័យ ស៊ីអេអូ។

**Compliance Advisor/Ombudsman**
**2121 Pennsylvania Ave., N.W.**
**Washington, D.C. 20433**
**U.S.A.**

## ដំណើរការដោះស្រាយវិវាទមួយបានចាប់ផ្តើម

### ការផ្អាកឈូសឆាយដីធ្លីបន្ថែមទៀត

នៅពេលចាប់ផ្តើមដំណើរការដំបូង ក្រុមហ៊ុនហ៊ាងអាញ់ យ៉ាឡាយ បានយល់ព្រមឈប់ឈូសឆាយដីនៅក្នុងសម្បទានរបស់ខ្លួនបន្ថែមទៀត រយៈពេល ៦ខែ ដើម្បីអនុញ្ញាតឱ្យដំណើរការសន្ទនាអាចមានការវិវឌ្ឍន៍ទៅមុខទៀតបាន។ ក្រោយរយៈពេល ៦ខែ ក្រុមហ៊ុន បានប្តេជ្ញាពន្យារការឈូសឆាយនេះ រហូតដល់ពេលដែលពួកគេអាចដោះស្រាយវិវាទនេះ ជាមួយសហគមជិតខាងរបស់ខ្លួន។



### ការរៀបចំសម្រាប់ការសម្របសម្រួល

នៅចន្លោះខែឧសភា និង ខែសីហា ឆ្នាំ២០១៤ ការិយាល័យ ស៊ីអេអូ បានរៀបចំវគ្គបុរេសម្របសម្រួលមួយចំនួនជូនភាគី ដើម្បីរៀបចំត្រៀមលក្ខណៈសម្រាប់កិច្ចសន្ទនា។ នៅពេលនេះ ភាគីបានធ្វើការជ្រើសរើសអ្នកតំណាងសហគមន៍ ព្រមទាំងកំណត់អំពីវិធានមូលដ្ឋាន និង របៀបទំនាក់ទំនងជាមួយរដ្ឋាភិបាលពាក់ព័ន្ធគ្រប់កម្រិត។

### ការធានាឱ្យមានកិច្ចគាំទ្រពីរាជរដ្ឋាភិបាល

ភាគីទាំងសងខាង បានស្វែងរក និង ចង់ឱ្យមានកិច្ចគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជាចំពោះដំណើរការនេះ។ ដូច្នេះ ការិយាល័យ ស៊ីអេអូ បានជួបជាមួយបុគ្គលិកសំខាន់ៗនៅឯក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ សាលាខេត្ត និង មន្ទីរពាក់ព័ន្ធ ដើម្បីជូនដំណឹងអំពីដំណើរការ ព្រមទាំងស្វែងរកកិច្ចគាំទ្រពីពួកគេ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ការិយាល័យ ស៊ីអេអូ បានទទួលលិខិតមួយច្បាប់ពីក្រសួងមហាផ្ទៃ ដែលបញ្ជាក់អំពីកិច្ចគាំទ្ររបស់ក្រសួង ចំពោះដំណើរការរបស់ការិយាល័យ ស៊ីអេអូ។




### ការកសាងសមត្ថភាព

ដោយមានកិច្ចគាំទ្រពីរាជរដ្ឋាភិបាល ដំណើរការដោះស្រាយវិវាទ បានចាប់ផ្តើមក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ដោយបានផ្តល់ការបណ្តុះបណ្តាលកសាងសមត្ថភាពជូនដល់ភាគីអំពីយន្តការដោះស្រាយវិវាទ និងបច្ចេកទេសចរចារ។ ស្របគ្នានេះដែរ និង នៅក្នុងដំណើរការទាំងមូល អង្គការតំណាងដែលជាទីប្រឹក្សារបស់សហគមន៍ បានគាំទ្រដល់អ្នកតំណាងសហគមន៍ ព្រមទាំងបានជួយពួកគេក្នុងការចូលរួមនៅក្នុងដំណើរការ។

### អ្នកតំណាង

ក្នុងខែធ្នូ ឆ្នាំ២០១៤ សហគមរងផលប៉ះពាល់នីមួយៗ បានជ្រើសរើសអ្នកតំណាងពីភូមិផ្សេងៗគ្នារបស់ពួកគេ តាមរយៈកម្រងនៃកិច្ចប្រជុំតាមភូមិមួយចំនួន ដែលមានការចូលរួមពីក្រុមការងាររបស់ការិយាល័យ ស៊ីអេអូ។ ភូមិនីមួយៗបានជ្រើសរើសអ្នកតំណាងមួយក្រុម ដែលមានសមាជិកប្រមាណ ៩ នាក់ និងអ្នកតំណាងស្ទួលចំនួន ២នាក់ ដើម្បីចូលរួមកិច្ចប្រជុំ។

**Compliance Advisor/Ombudsman**
**2121 Pennsylvania Ave., N.W.**
**Washington, D.C. 20433**
**U.S.A.**

## វិធានមូលដ្ឋាន

កិច្ចប្រជុំលើកដំបូងរវាងភាគី ដើម្បីរៀបចំដំណើរការចរចារមួយ បានធ្វើឡើងក្នុងខែមករា ឆ្នាំ២០១៥ ដែលក្នុងអំឡុងពេលនេះ ភាគីបានឯកភាពចុះហត្ថលេខាលើកម្រងវិធានមូលដ្ឋានមួយ ដើម្បីប្រើប្រាស់ជាមគ្គុទ្ទេសក៍ណែនាំចំពោះដំណើរការ។

## ការឯកភាពទៅលើរចនាសម្ព័ន្ធនៃដំណើរការ

ខណៈពេលដែលដំណើរការសម្របសម្រួលមានការវិវឌ្ឍន៍ទៅមុខ ភាគីអាចផ្តល់ការបញ្ជាក់កាន់តែច្បាស់អំពីភូមិជាក់ស្តែងដែលរងផលប៉ះពាល់ពីគម្រោងរបស់ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ។ ដូច្នេះ សហគមន៍ត្រូវបានចងក្រងជា ៣ ក្រុម ៖

- ក្រុមទី១ ៖ ភូមិចំនួន៣ មិនរងផលប៉ះពាល់ពីក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ និង ស្ថិតនៅក្រៅសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន។
- ក្រុមទី២ ៖ ភូមិចំនួន៣ ត្រូវបានរកឃើញថាស្ថិតនៅក្នុងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ ប៉ុន្តែមិនទាន់រងផលប៉ះពាល់នៅឡើយ។
- ក្រុមទី៣ ៖ ភូមិចំនួន១១ ដែលបានរងផលប៉ះពាល់រួចទៅហើយ ដោយសកម្មភាពរបស់ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ។

ក្នុងខែមីនា ឆ្នាំ២០១៥ ភាគីបានអនុម័តទៅលើកិច្ចព្រមព្រៀងសម្របសម្រួលមួយ និងបានចេញសេចក្តីថ្លែងការណ៍រួមលើកដំបូងរបស់ពួកគេ ទាក់ទងនឹងដំណើរការសម្របសម្រួលនេះ។

សូមមើលសេចក្តីថ្លែងការណ៍រួមលើកទី១។
(អាចរកមើលបានតាមរយៈគេហទំព័រ www.cao-ombudsman.org)

## កិច្ចព្រមព្រៀងបឋម

## ភូមិក្រុមទី១ ដែលមិនរងផលប៉ះពាល់ដោយផ្ទាល់ពីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ

ក្នុងខែកក្កដា ឆ្នាំ២០១៥ ការផ្តោះប្តូរព័ត៌មានរវាងភាគីបានជួយកំណត់ឱ្យដឹងថា មានភូមិចំនួន៣ដែលបានចូលរួមដាក់ពាក្យបណ្តឹង ពុំរងផលប៉ះពាល់ដោយផ្ទាល់ពីប្រតិបត្តិការរបស់ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយឡើយ។ ដូច្នេះ ពួកគេលែងចូលរួមនៅក្នុងដំណើរការរបស់ការិយាល័យ ស៊ីអេអូ ទៀតហើយ។

សូមមើលសេចក្តីថ្លែងការណ៍រួមលើកទី២។
(អាចរកមើលបានតាមរយៈគេហទំព័រ www.cao-ombudsman.org)

## ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ បានធ្វើការប្តេជ្ញាចិត្តមួយចំនួន

ក្នុងខែកញ្ញា ឆ្នាំ២០១៥ ក្រុមហ៊ុនបានធ្វើការប្តេជ្ញាចិត្តមួយចំនួន ក្នុងនោះរួមមានដូចជា ការមិនចូលរួមនៅក្នុងសកម្មភាពឈូសឆាយ ឬ អភិវឌ្ឍន៍បន្ថែមទៀតចំពោះដីសម្បទានរបស់ខ្លួន ដើម្បីជៀសវាងបង្កផលប៉ះពាល់អវិជ្ជមានបន្ថែមទៅលើភូមិទាំង១១។ ការប្តេជ្ញាចិត្តទាំងនេះ បានត្រួសត្រាយផ្លូវសម្រាប់កិច្ចព្រមព្រៀងបន្ថែមទៀត ជាមួយភូមិចំនួន៣ទៀត ដែលស្ថិតនៅក្នុងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ប៉ុន្តែ ភូមិទាំង៣នឹងមិនរងផលប៉ះពាល់ឡើយ ដោយសារតែក្រុមហ៊ុនបានប្តេជ្ញាចិត្តមិនធ្វើការឈូសឆាយ និង អភិវឌ្ឍន៍ទៅលើដីបន្ថែមទៀត។

កិច្ចព្រមព្រៀងរវាងភាគី បានរៀបចំផែនការឱ្យមានដំណើរទស្សនកិច្ចរួមគ្នាមួយទៅកាន់មូលដ្ឋាន ដើម្បីឱ្យសហគមន៍ និងក្រុមហ៊ុន អាចបញ្ជាក់អំពីព្រំប្រទល់ដីរបស់ពួកគេ ព្រមទាំងការប្តេជ្ញារបស់ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ ក្នុងការបង្កើតឱ្យមាននូវយន្តការដោះស្រាយបណ្តឹងសារទុក្ខពីសហគមន៍ សម្រាប់ប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងប្រទេសកម្ពុជា។

**Compliance Advisor/Ombudsman**
**2121 Pennsylvania Ave., N.W.**
**Washington, D.C. 20433**
**U.S.A.**

- សូមមើលសេចក្តីថ្លែងការណ៍រួមលើកទី៣។ (អាចរកមើលបានតាមរយៈគេហទំព័រ www.cao-ombudsman.org)

បន្ថែមពីនេះទៀត ក្នុងខែកញ្ញា ឆ្នាំ២០១៥ នៅឯកិច្ចប្រជុំរួមមួយក្នុងខេត្តសៀមរាប ក្រុមហ៊ុន និងសហគមន៍ទាំង១១ ដែលរងផលប៉ះពាល់ដោយផ្ទាល់ខ្លាំងបំផុត សម្រេចបានកម្រងនៃកិច្ចព្រមព្រៀងមួយចំនួនសម្រាប់ក្រុមភូមិទាំងនេះ ក្នុងនោះរួមមានផែនការសម្រាប់អនុវត្តដំណើរទស្សនកិច្ចរួមគ្នាទៅកាន់បណ្តាភូមិនានា ការស្តារឡើងវិញនូវប្រភពទឹក ការជួសជុលផ្លូវនិងស្ពាន និងការឯកភាពថានឹងផ្តល់សំណង ឬ ប្រគល់ដីទៅឱ្យភូមិវិញ ប្រសិនបើក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយបានធ្វើការឈូសឆាយ ឬ អភិវឌ្ឍន៍លើដីសហគមន៍។

- សូមមើលសេចក្តីថ្លែងការណ៍រួមលើកទី៤។ (អាចរកមើលបានតាមរយៈគេហទំព័រ www.cao-ombudsman.org)

**កិច្ចព្រមព្រៀងនៅឯខេត្តសៀមរាប**

- ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយនឹងប្រើផលិតផលគីមីដែលស្របតាមលិខិតបទដ្ឋានបរិស្ថានតែប៉ុណ្ណោះ។
- ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ នឹងជួសជុល និង ថែទាំផ្លូវនិងស្ពានដែលអ្នកភូមិប្រើ ដែលទទួលរងផលប៉ះពាល់ដោយប្រតិបត្តិការរបស់ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ។
- ធ្វើទស្សនកិច្ចរួមគ្នាដោយគូភាគី និង ភាគីពាក់ព័ន្ធ រួមមានអង្គការមិនមែនរដ្ឋាភិបាលជាទីប្រឹក្សា ការិយាល័យស៊ីអេអូ និងអាជ្ញាធរមូលដ្ឋាន ទៅភូមិនីមួយៗទាំង១១ ដើម្បីកំណត់ព្រំប្រទល់នៃចំការរបស់ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ និង ព្រំប្រទល់នៃភូមិដែលរងផលប៉ះពាល់។
- ប្រសិនបើតាមរយៈការធ្វើទស្សនកិច្ចរួមគ្នា រកឃើញថាក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ បានឈូសឆាយ និងអភិវឌ្ឍន៍ដីដែលជាកម្មសិទ្ធិរបស់អ្នកភូមិ នោះក្រុមហ៊ុននឹង (ក) ផ្តល់សំណងជាប្រាក់ដល់អ្នកភូមិសម្រាប់ដីនេះ និង (ខ) ប្រសិនបើអ្នកភូមិមិនព្រមទទួលយកសំណងទេ ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ នឹងប្រគល់ដីជូនអ្នកភូមិវិញ និង
- ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ យល់ព្រមផ្តល់ការគាំទ្រដល់អ្នកភូមិក្នុងការស្នើសុំប្លង់កម្មសិទ្ធិដីរបស់ពួកគេ។
- ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ បានយល់ព្រមស្តារឡើងវិញនូវប្រភពទឹកដែលរងផលប៉ះពាល់ រួមទាំងធនធានត្រីដែលបានបាត់បង់ សម្រាប់ភូមិទាំង ១៤ ដែលបានចូលរួមក្នុងដំណើរការដោះស្រាយវិវាទរបស់ ស៊ីអេអូ (រួមមានភូមិទាំង ១១ ខាងលើ និង ភូមិកេត ភូមិណាយ និង ភូមិកាជូត)។
- ដោយទទួលស្គាល់នូវផលប៉ះពាល់ដែលបង្កដោយគំរោងចំការកៅស៊ូរបស់ក្រុមហ៊ុន ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយសូមខមារទោសដោយស្មោះ ចំពោះភូមិទាំង ១៤ និងសូមផ្តល់ជូនគោមួយក្បាល (ទម្ងន់ ៤០០ គីឡូក្រាម) និងថវិកា ៥០០ ដុល្លា ដល់ភូមិនីមួយៗ សម្រាប់ប្រើប្រាស់ក្នុងពិធីសែនព្រេនអារក្ស ។

## ការអនុវត្តន៍កិច្ចព្រមព្រៀងបឋម

### ពិធីសុំខមាទោស និងកិច្ចគាំទ្រសម្រាប់ពិធីនេះ

ដើម្បីចាប់ផ្តើមអនុវត្តកិច្ចព្រមព្រៀងអន្តរកាល ភាគីអង្គការតំណាងដែលជាទីប្រឹក្សា និង តំណាងរដ្ឋាភិបាលថ្នាក់ខេត្ត ព្រមទាំងក្រុមការងារនៃការិយាល័យស៊ីអេអូ បានចូលរួមនៅក្នុងពិធីសែនព្រេនមួយ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥។ ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ បានសុំទោសជាសាធារណៈចំពោះសហគមន៍ជនជាតិដើមភាគតិច សម្រាប់ផលប៉ះពាល់ទៅលើប្រពៃណីរបស់ពួកគេ។

**Compliance Advisor/Ombudsman**
**2121 Pennsylvania Ave., N.W.**
**Washington, D.C. 20433**
**U.S.A.**

## ដំណើរទស្សនកិច្ចទៅកាន់មូលដ្ឋាន ដើម្បីបញ្ជាក់អំពីព្រំប្រទល់ដី

ក្នុងខែមករា ឆ្នាំ២០១៦ អ្នកតំណាងក្រុមហ៊ុន និង សហគមន៍ សមាជិករដ្ឋាភិបាលថ្នាក់ខេត្ត អង្គការតំណាងដែលជាទីប្រឹក្សា និង ក្រុមការងារនៃការិយាល័យ ស៊ីអេអូ បានធ្វើដំណើរទស្សនកិច្ចរួមគ្នាទៅកាន់ភូមិចំនួន៣ ដំបូងគេ។ ភាគីនីមួយៗបានផ្តល់អ្នកឯកទេសផ្នែកផែនទីរបស់ពួកគេដោយខ្លួនឯង។

ក្នុងខែមិថុនា ឆ្នាំ២០១៦ ក្រុមហ៊ុន និង អ្នកតំណាងសហគមន៍ អង្គការតំណាងដែលជាទីប្រឹក្សារបស់សហគមន៍ ក្រុមការងាររបស់ការិយាល័យ ស៊ីអេអូ និង សមាជិកក្រុមការងាររបស់រាជរដ្ឋាភិបាល បានចុះធ្វើទស្សនកិច្ចទៅកាន់ភូមិមួយទៀត។

## ក្រុមការងាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារមួយ ដើម្បីជួយដល់ភាគីក្នុងការកំណត់តំបន់ដែលត្រូវបានចោទប្រកាន់ថាមានភាពត្រួតស៊ីគ្នា រវាងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ និង ដីដែលសហគមន៍ជនជាតិដើមភាគតិចប្រើប្រាស់តាមបែបប្រពៃណី។
រាជរដ្ឋាភិបាលនឹងចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទតាមសំណើរបស់ភាគីទាំង២ ព្រមទាំងជួយដល់ពួកគេក្នុងការស្វែងរកដំណោះស្រាយមួយប្រកបដោយសន្តិវិធី។

## ជំហានបន្ទាប់

ការិយាល័យ ស៊ីអេអូ បាននិងកំពុងសម្របសម្រួលកិច្ចសន្ទនាមួយ រវាងអ្នកពាក់ព័ន្ធទាំងអស់ជារៀងរាល់ខែ។ បច្ចុប្បន្ន ដំណើរការសម្របសម្រួលរបស់ការិយាល័យ ស៊ីអេអូ កំពុងបន្ត។
ព័ត៌មានបន្ថែមអំពីការិយាល័យ ស៊ីអេអូ អាចរកមើលបាននៅឯគេហទំព័រ៖ www.cao-ombudsman.org។

ទំព័រអំពីករណីប្រទេសកម្ពុជា/VEIL អាចចូលមើលបានដោយផ្ទាល់តាមរយៈគេហទំព័រ http://www.cao-ombudsman.org/cases/case_detail.aspx?id=212 ឬ http://bit.ly/2acRXwl។